

# ដំណាំម្រះ

## ការរៀបចំដីដាំ

រៀបចំរងទំហំ១ម៉ែត្រ (ត្រូវមានកំពស់ ៣០ សង់ទីម៉ែត យ៉ាងតិចនៅរដូវវស្សា)ពង្រាយដីលាមកគោស្ងួតរឺដីកំប៉ុស្ត៍ និង ដីកែងៗពេញរងហើយកាប់ប្រចល់ជាមួយដីអោយសព្វល្អគ្រប រងដោយគំរបដីផ្លាស់ស្ទិក រឺ ចំបើងអោយបានកំរាស់យ៉ាងតិច៥ សង់ទីម៉ែត្រដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី។



*ការបង្ហូរទឹកចូលធ្វើឲ្យដីមានសំណើម*

## ការបណ្តុះគ្រាប់

ត្រាំគ្រាប់ក្នុងងទឹកក្តៅឧណ្ហៗ រយៈពេលពី ១៥ ទៅ ២០ នាទី (រដូវក្តៅអាចដាក់គ្រាប់បណ្តុះតែម្តងបាន) ពង្រាយគ្រាប់ ដែលបានត្រាំហើយលើក្រណាត់សើមហើយដក់ទឹក មូរក្រណាត់ នេះរួចយកទុកក្នុងកន្លែងងងឹតត្រូវរក្សាក្រណាត់ដែលបានមូរឲ្យ មានសំណើម តែមិនត្រូវអោយសើមពេកទេបន្ទាប់ពីផ្អាប់២ថ្ងៃ គ្រាប់នឹងបែកមាត់ នោះយើងអាចយកគ្រាប់នេះទៅដាក់បណ្តុះ ក្នុងកន្ទោង រឺថាសបណ្តុះបាន។

## ការបណ្តុះកូន

រៀបចំកន្ទោងបណ្តុះ (ស្លឹកត្នោត រឺស្លឹកចេក) រឺ ថាស បណ្តុះ យកដីមានជីជាតិ(ដីដំបូក)១ភាគ ដីកំប៉ុស្តិ៍រឺដីលាមក គោដែលរលួយ១ភាគ និងផេះអង្កាម១ ភាគ លាយជាមួយគ្នា ហើយ យកទៅលីងអោយក្តៅបំផុត រួចទុកអោយត្រជាក់ទើប ដាក់កន្ទោង។ បណ្តុះតែ១គ្រាប់ក្នុងមួយកន្ទោង ត្រូវគ្របសំណាញ់ សត្វល្អិត និងធ្វើដំបូលគ្របអំពីស្លឹកដូងឬសំណាញ់កាត់ពន្លឺនៅ រដូវក្តៅ។ រដូវវស្សាត្រូវធ្វើដំបូលការពារទឹកភ្លៀង ពីព្រោះកូន ដំណាំនៅតូចមិនត្រូវការពន្លឺ និងទឹកច្រើនទេ។ស្រោចទឹក១ថ្ងៃ មួយដងនៅពេលព្រឹក (បើទុកដីបណ្តុះស្ងួត គ្រាប់មិនអាចដុះ បានទេ បើកូនដុះហើយក៏នៅក្រិនដែរ)



## ការដាំកូនម្រះ

កូនអាយុបាន ៧ថ្ងៃ អាចយកទៅដាំបាន ត្រូវដាក់កូន ម្រះអោយត្រូវចំពន្លឺថ្ងៃបានចំនួន២-៣ថ្ងៃមុនដាំដើម្បីអោយកូន រឹងមាំល្អហើយផ្សាំនិងអាកាសធាតុខាងក្រៅបានស្រោចទឹកកូន ម្រះឲ្យសើមល្មមនៅពេលព្រឹក ហើយចាប់ផ្តើមដាំកូនម្រះនៅ ពេលរសៀលយកកូនចេញពីកន្ទោង រឺថាសបណ្តុះដោយប្រុង ប្រយ័ត្នបំផុត មិនត្រូវអោយដាច់ឬសកូនម្រះឡើយត្រូវដឹងថាកូន ម្រះត្រូវការស្រោចទឹកអោយបានគ្រប់គ្រាន់ ជាពិសេសរវាងពី ២ -៣ អាទិត្យបន្ទាប់ពីដាំកូនហើយត្រូវដោតទ្រើងភ្លាមបន្ទាប់ពីដាំ ពីព្រោះម្រះដុះលូតលាស់លឿនណាស់ បើទុកអោយវាធំទើបដោត ទ្រើងធ្វើអោយដាច់ឬសដំណាំ



## ការថែទាំ

គួរកាត់ស្លឹកដែលនៅក្បែរដីចេញ និងកាត់ខ្នែងទាំងឡាយ ណាដែលនៅកំពស់ពីដីកន្លះម៉ែត្រចុះមកក្រោមត្រូវស្រោចទឹក ឲ្យបានគ្រប់គ្រាន់នៅពេលព្រឹក ជៀសវាងស្រោចទឹកច្រើនពេក ធ្វើឲ្យដីសើមជ្រុលនៅពេលថ្ងៃល្ងាច វាអាចបង្កអោយមានបញ្ហា ដល់ ដំណាំបាន។





## ការប្រើប្រាស់ជី ១៥០.៩០.១៣០ (បើដាក់ជីត្រូវស្រោចទឹក ទើបដំណាំអាចចាប់យកជីបាន)

| ពេលវេលា | ប្រភេទជី/១ដើម | កន្លែងដែលត្រូវដាក់ជី |
|---|---|---|
| មុនដាំ | ជីលាមកសត្វ ១.៥ គីឡូក្រាម ជី អិន ប៉េ កា (១៥.១៥.១៥)១ស្លាបព្រាបាយកំពុង (១៥ក្រាម) | ពង្រាយលើរង |
| ការដាំកូន | តែមួយដើម ក្នុងមួយរណ្តៅ | |
| ២អាទិត្យបន្ទាប់ដាំ | ជី អិន ប៉េ កា(១៥. ១៥.១៥)១ស្លាបព្រាបាយស្មើ(១០ក្រាម)ជីអ៊ុយរ៉េ ១ស្លាបព្រាបាយស្មើ (១០ក្រាម) | កប់ជីរាក់ៗ ចំងាយពីគល់កន្លះតឹក |
| ៤អាទិត្យបន្ទាប់ដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)១ស្លាបព្រាបាយស្មើ (១០ក្រាម ជីអ៊ុយរ៉េ ១ស្លាបព្រាបាយស្មើ (១០ក្រាម) | កប់ជីរាក់ៗ ចំងាយពីគល់១តឹក |
| ៦ អាទិត្យបន្ទាប់ដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)១ស្លាបព្រាបាយស្មើ (១០ក្រាម) ជីប៉ូតាស្យូម កន្លះស្លាបព្រាបាយ | កប់ជីរាក់ៗ |
| ៨អាទិត្យបន្ទាប់ដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)១ស្លាបព្រាបាយស្មើ (១៥ក្រាម) ជីប៉ូតាស្យូម កន្លះស្លាបព្រាបាយ (៥ក្រាម) | កប់ជីរាក់ៗ ចំងាយពីគល់១តឹកកន្លះ |
| ១០អាទិត្យប្ទន្ទាប់ដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)បាយកំពុង (១៥ក្រាម) | កប់ជីរាក់ៗចំងាយពីគល់១តឹកកន្លះ |
| ១២អាទិត្យប្ទន្ទាប់ដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)១ស្លាបព្រាបាយកំពុង (១៥ក្រាម) | កប់ជីរាក់ៗចំងាយពីគល់១តឹកកន្លះ |

## ការការពារជំងឺនិងសត្វល្អិត

### រុយចោះផ្លែ:

ត្រូវខ្ចប់ក្តិបម្រះដោយថង់ រឺក្រដាស់នៅពេលផ្កាក្តិបម្រះចាប់ផ្តើមស្រពោន។ កុំទុកក្តិបផ្ការហូតដល់ជ្រុះទើបប្រកថង់ រឺក្រដាស់។ ត្រូវបេះផ្លែដែលខូចៗហើយកប់ផ្លែទាំងនេះចោល។ បើទុកផ្លែដែលខូចនៅក្នុងចំការ រឺចោលក្បែរចំការ នោះកូនដង្កូវដែលញាស់ចេញមកក្លាយជារុយចោះផ្លែកាន់តែច្រើនឡើងហើយបំផ្លាញកាន់តែខ្លាំងជាមុន។

### ការពារនិងការកំចាត់ជំងឺលឿងស្លឹក:

ចាប់តាំងពីកូនម្រះដុះ ត្រូវបាញ់ថ្នាំផ្សិត៥ថ្ងៃម្តងនៅរដូវភ្លៀង និង៧ថ្ងៃម្តងនៅរដូវប្រាំង ។ បាញ់ថ្នាំផ្សិតនៅម៉ោង៤ទៅម៉ោង៥ល្ងាច។ ដោយសារផ្សិតជំងឺនៅខាងក្រោមស្លឹក យើងត្រូវបាញ់ថ្នាំពីខាងក្រោមស្លឹកទៅខាងលើ។ បើម្រះមានជំងឺផ្សិតហើយយើងត្រូវកាត់ស្លឹកទាំងនេះចេញសិនមុន និងបាញ់ថ្នាំផ្សិត។ ស្លឹកនេះយកទៅកប់ចោល រឺធ្វើជាជីកុំប៉ុស្តបាន។ កុំទុកស្លឹកនេះនៅក្នុងចំការ វាឆ្លងទៅដើមផ្សេងទៀត។ កុំប្រើថ្នាំឈ្មោះកុំចាត់សត្វល្អិតនិងជំងឺដដែលៗ វាធ្វើអោយសត្វល្អិតនិងជំងឺមានភាពធន់ទ្រាំជាមួយថ្នាំ ពិបាកកំចាត់នៅពេលក្រោយ។ កុំប្រើថ្នាំពុលលាយចូលគ្នានៅពេលបាញ់ វាធ្វើអោយថ្នាំគ្មានប្រសិទ្ធិភាព ហើយសត្វល្អិត ដង្កូវរហ័សសាំនិងថ្នាំ ពិបាកកំចាត់លើកក្រោយ។ កុំដាំម្រំលើះដីដដែលៗនាំអោយកើតមានជំងឺ និងសត្វល្អិតកាន់តែច្រើនជាហេតុពិបាកកំចាត់វា។ សូមដកម្រះយកទៅដុតចោលភ្លាមបន្ទាប់ពីបញ្ចប់ប្រមូលផលហើយ។ កុំទុកដើមដែលឈប់ប្រមូលផលហើយនៅនឹងទ្រើងក្នុងចំការ។ ពីព្រោះវាជាជំរកសត្វល្អិតនិងជំងឺបំផ្លាញទៅដំណាំផ្សេងទៀតបាន។

## ការប្រមូលផល

យើងអាចកាត់ផ្លែបាននៅពេលណាដែលវាមានពណ៌រលោងនិងក្រឡាប្រេះល្អ តែទំហំផ្លែអាស្រ័យតាមទីផ្សារ។ ត្រូវកាត់ផ្លែនៅពេលព្រឹក ហើយត្រូវទុកផ្លែនោះនៅក្នុងម្លប់បន្ទាប់ពីកាត់ហើយភ្លាម ជៀសវាងផ្លែរហ័សស្វិត ស្រកទំងន់៕

### ឯកសារពិគ្រោះ


- សៀវភៅណែនាំអំពីបច្ចេកទេសដំណាំបន្លែ, ២០១១
- សៀវភៅណែនាំបច្ចេកទេសកសិករ ផលិតកម្មដំណាំបន្លែ, ២០១៣



សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោម:
លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧




ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ដំណាំម្រះ




សហការផលិតដោយ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់-ក្រខាក់បៃតង ខេត្តសៀមរាប
២០១៣